## ជនដែលស្ថិតក្នុងកន្លែងឃុំឃាំង និងក្នុងស្ថាប័នផ្សេងទៀត

- ជនដែលត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន រួមទាំងនៅក្នុងពន្ធនាគារ ការឃុំខ្លួនបណ្តោះអាសន្ន ស្ថាប័ន ឬកន្លែងឃុំខ្លួនជនអន្តោប្រវេសន៍ មជ្ឈមណ្ឌលនីតិសម្បទាគ្រឿងញៀនដោយបង្ខំ និងកន្លែងឃុំឃាំងផ្សេងទៀត មានហានិភ័យខ្ពស់ក្នុងការឆ្លងរោគក្នុងករណីមានជំងឺផ្ទុះឡើង។ មានហានិភ័យខ្ពស់នៃការចម្លងរោគ ហើយការដាក់ឱ្យនៅឃ្លាតឆ្ងាយពីគ្នា គឺពិបាកនឹងធ្វើទៅបាន។ ស្ថានភាពរបស់ពួកគេ គួរត្រូវបានដោះស្រាយជាពិសេស នៅក្នុងការធ្វើផែនការ និងការឆ្លើយតបទៅនឹងវិបត្តិ។
- រដ្ឋទាំងឡាយ គួរអនុម័តវិធានការពិសេសផ្សេងៗ ដើម្បីធានាការទទួលបានព័ត៌មាន និងសមភាពក្នុងការបង្ការ និងការថែទាំសុខភាពដទៃទៀត ដល់បុគ្គលគ្រប់រូប ដែលត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន។
- រដ្ឋទាំងឡាយ គួរស្វែងរកជម្រើសជាបន្ទាន់សម្រាប់ការដោះលែង និងជម្រើសផ្សេងៗក្នុងការឃុំខ្លួន ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់នៅក្នុងកន្លែងឃុំឃាំង រួមទាំងជនទាំងឡាយដែលបានប្រព្រឹត្តបទល្មើសតូចតាច បទលហុ និងអហិង្សា ជនដែលនឹងត្រូវដល់ថ្ងៃដោះលែងឆាប់ៗ ជនជាប់ឃុំក្នុងការិយាល័យអន្តោប្រវេសន៍ និងជនត្រូវបានឃុំខ្លួនដោយសារតែឋានៈអន្តោប្រវេសន៍របស់ខ្លួន ជនដែលមានបញ្ហាស្ថានភាពសុខភាពរ៉ាំរ៉ៃ និងជនដែលស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ឬការឃុំខ្លួនផ្នែករដ្ឋបាល។ ជនដែលត្រូវបានឃុំខ្លួនដោយគ្មានមូលដ្ឋានច្បាប់ គួរតែត្រូវបានដោះលែង ក៏ដូចជា ជនដែលស្ថិតនៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀនដែលបង្ខំ ឬកម្មវិធីព្យាបាល។
- គួរតែមានការផ្អាកបណ្តោះអាសន្នចំពោះកុមារដែលត្រូវបញ្ជូនទៅកន្លែងឃុំឃាំង ហើយរដ្ឋទាំងឡាយ គួរដោះលែងកុមារទាំងអស់ចេញពីកន្លែងឃុំឃាំង ដែលអាចត្រូវបានដោះលែងដោយសុវត្ថិភាព។
- ស្ថានភាពជនពិការ និងមនុស្សចាស់ដែលរស់នៅតាមស្ថាប័នផ្សេងៗពិតជាធ្ងន់ធ្ងរណាស់។ ការដាក់កម្រិតលើទំនាក់ទំនងជាមួយគ្រួសារ អាចត្រូវបានរាប់ជាផ្នែកមួយនៃវិធានការបន្ទាន់ខាងសុខភាព ប៉ុន្តែអាចបណ្តាលឱ្យជនពិការ និងមនុស្សចាស់ ត្រូវប្រឈមនឹងការធ្វេសប្រហែស និងការរំលោភបំពានថែមទៀត។ ការគាំទ្រតាមសហគមន៍ និងឧបករណ៍បង្ការអំពើហិង្សាដែលមាន គួរតែត្រូវបានអនុវត្ត។
- សមមើល<u>គោលការណ៍ណែនាំបណ្តោះអាសន្នស្តីពីជំងឺកូវីដ-១៩៖ ផ្តោតលើជនដែលត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន</u>
- សូមមើល<u>កំណត់បច្ចេកទេសៈ ជំងឺកូវីដ-១៩ និងកុមារត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន</u> (PDF)